| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | សិក្សាសង្គម |
| **ប្រធានបទ** | គំនូរ និងសកម្មភាពកសាងៈ |
| **ចំណងជើងមេរៀន** | សកម្មភាពកសាង៖<br>សូនរូបមេរោគដោយប្រើដីឥដ្ឋ |
| **កម្រិត** | មធ្យម ៣០ នាទី |
| **គោលបំណង** | -ដើម្បីឱ្យកុមារមានការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាពដោយប្រើដីឥដ្ឋសូនជារូបផ្សេងៗ។ |
| **បំណិនសម្បទា** | -សូនរូបឱ្យបានត្រឹមត្រូវតាមការណែនាំ។ |
| **ចរិយាសម្បទា** | ព្យាយាម អំណត់ សហការ ចូលរួម<br>និងទទួលស្គាល់ស្នាដៃរបស់ខ្លួន និងអ្នកដទៃ។ |
| **គ្រូបង្រៀន** | -ធ្វើដីឥដ្ឋសម្រាប់សូនរូបបោះពុម្ពរូបភ្នែកធ្វើការម៉្យ៉ាប្រមែប្រមូលរបស់របរសម្ភារៈមួយចំនួនដែលអាចប្រើសម្រាប់ដោត ចាក់បាន ដូចជា ទុយោ ឈើចង្កឹះតូចៗ<br>និងសម្ភារៈផ្សេងៗ។<br>បង្កើតជាគម្រូរសម្រាប់បង្ហាញដល់ក្មេងៗ។ |
| **កុមារ** | -ធ្វើជាក្រុម<br>-(ឬតាមស្ថានភាពជាក់ស្តែងពេលលេង) |

| រៀបចំ | -ដីឥដ្ឋ សម្ភារៈសម្រាប់ធ្វើភ្នែក ការ<br>-គម្រូវដែលបានធ្វើរួចសម្រាប់បង្ហាញទៅកាន់ពួកគេ |
|---|---|

| សកម្មភាពគ្រូបង្រៀន | មាតិកា | សកម្មភាពសិស្ស |
|---|---|---|
| 1. ប្រាប់ក្មេងៗថាពួកគេនឹងធ្វើការរួមគ្នាជាក្រុមដើម្បីបង្កើតរូបមេរោគ ឬបិសាចតូចៗដោយប្រើដីឥដ្ឋ។<br>2. បែងចែកក្មេងៗទាំងអស់ទៅជាក្រុមៗ ។<br>3. ពន្យល់ពួកគេថាអ្នកចង់ឱ្យក្មេងៗទាំងអស់ធ្វើការងារជាក្រុម ដូច្នេះហើយសមាជិកក្រុមទាំងអស់បង្កើតរូបមេរោគដូចៗគ្នា។ ពួកគេត្រូវសម្រេចចិត្តថាប្រើអ្វីសម្រាប់ចាក់ចូលទៅក្នុង<br>ដីឥដ្ឋ<br>(ដាក់ភ្នែកមុនគេបានល្អ)។ នៅពេលដែលក្មេងណាម្នាក់បានសម្រេចចិត្តថានឹងប្រើអ្វីធ្វើវា | 1. បង្ហាញក្មេងៗពីឧទាហរណ៍ និងពន្យល់របៀបធ្វើវា និងប្រាប់ពីសេចក្តីណែនាំដូចខាងក្រោម៖<br>• រូបរាង ដីឥដ្ឋ<br>• បិទការនៅលើភ្នែក<br>• ចាក់វត្ថុមួយចំនួននោះទៅលើដីឥដ្ឋដែលបានធ្វើវាឡើង ជាមេរោគ ឬជាបិសាចតូចៗ ។ | 1. ស្តាប់សេចក្តីណែនាំរបស់គ្រូ ។<br>2. នៅពេលដែលពួកគេធ្វើការជាក្រុមត្រូវពិភាក្សាគ្នា។<br>3. សម្រេចចិត្តវត្ថុមួយដែលអ្នកចង់ចោះចូលទៅក្នុងដីឥដ្ឋ និងត្រូវប្រាកដថាអ្នកទាំងអស់គ្នាយល់ព្រម។<br>4. បិទភ្នែកមុនគេ និង<br>5. យល់ព្រមដូចជាក្រុមត្រូវមានភ្នែកប៉ុន្មាន និងបិទការនៅកន្លែងណា<br>6. នៅពេលដល់វេនរបស់អ្នកត្រូវសម្រេចចិត្តឱ្យច្បាស់ជាមុនសិន និងពន្យល់ឱ្យច្បាស់ពីការចាក់វត្ថុ |

| | | |
|---|---|---|
| ក្មេងៗទាំងអស់នៅក្នុងក្រុមត្រូវធ្វើឱ្យដូចគ្នា។ តាមវិធីនេះដែរ ក្រុមនីមួយៗនឹងធ្វើរូបមេរោគខុសគ្នាក៏បានដែរ។ ចែកដីឥដ្ឋឱ្យទៅក្មេងៗ ភ្នែក កាវ និងវត្ថុសម្រាប់ចាក់លើដីឥដ្ឋ។<br>4. ចូរឱ្យក្មេងៗបែងចែកដីឥដ្ឋឱ្យសមាជិកក្រុមម្នាក់ៗបន្ទាប់មកចាប់ផ្តើមលេង ។<br>5. រំលឹកពួកគេ ថានៅពេលដល់វេនពួកគេឡើងពន្យល់គួរតែពន្យល់ដោយប្រយ័ត្នប្រយែងថាត្រូវដាក់វត្ថុនោះនៅកន្លែងណា។ នៅពេលដែលមិនទាន់ដល់វេនរបស់ពួកគេពួកគេគួរតែស្តាប់ដោយយកចិត្តទុកដាក់ចំពោះការណែនាំរបស់កុមារដ៏ទៃទៀត។<br>6. នៅពេលដែលពួកគេធ្វើរួចរាល់ហើយនោះប្រាប់ពួកគេ | | 7. និងនៅពេលដែលមិនមែនជាវេនរបស់អ្នក អ្នកត្រូវស្តាប់ប្រុងប្រយ័ត្នពីសេចក្តីណែនាំរបស់ក្មេងដដែទៀត និងចម្លងឱ្យបានស្អាតល្អ<br>8. នេះគឺជាការធ្វើការងារជាក្រុមដោយសហការយ៉ាងល្អ<br>9. នៅពេលដែលពួកគេធ្វើរួចរាល់ហើយនោះ ប្រាប់ពួកគេថាត្រូវដាក់រូបនៅទីណា ដើម្បីឱ្យវឆាប់ស្ងួត។<br>10. ប្រសិនបើមានពេលក្នុងការលេងទៀត សូមឱ្យពួកគេធ្វើដោយខ្លួនឯងម្តងទៀត<br>11. នៅពេលដែលពួកគេបានលេងល្បែងនេះចប់ហើយនោះ ចូរឱ្យពួកគេរៀបចំឱ្យបានស្អាត និងបោះចោលសម្រាមឱ្យមានរបៀបរៀបរយផងជាការស្រេច។ |

| | | |
|---|---|---|
| ថាត្រូវដាក់រូបនៅទីណាដើម្បីឱ្យវាឆាប់ស្ងួត។<br>7. ប្រសិនបើមានពេលក្នុងការលេងទៀតសូមឱ្យពួកគេធ្វើដោយខ្លួនឯងម្តងទៀត ។<br>8. នៅពេលដែលពួកគេបានលេងល្បែងនេះចប់ហើយនោះ ចូរឱ្យពួកគេរៀបចំឱ្យបានស្អាតនិងបោះចោលសម្រាមឱ្យមានរបៀបរៀបរយផងជាការស្រេច។ | | |